**Remarks**

**Hon. Dr. NGUON Nhel, Second-Vice President of**

**the National Assembly of the Kingdom of Cambodia and the Chairman of the Organizing Committee At Closing Ceremony of the 8th Asian Parliamentary Assembly (APA) under the theme:**

**"Promoting Peace, Reconciliation and Dialogue in Asia"**

**11 December 2015, Phnom Penh**

---

My respects to:

- Honorable Samdech Akka Moha Ponhea Chakrei Heng Samrin, President of the Asian Parliamentary Assembly and President of the National Assembly of the Kingdom of Cambodia,
- Honorable Heads and Members of Delegations of the APA Member Parliaments,
- Honorable Delegations of Observer Parliaments and Partner Organizations of APA;
- His Excellency Dr. MASOUD Islami, Acting Secretary-General of APA;
- Excellencies, National and International Distinguished Guests, Ladies and Gentlemen;

**Good afternoon!**

1. Today is the last day of the 8th APA Plenary Session and also the day we all feel relaxed and happy after performing very active and challenging tasks for the common benefit of our Asian region vever the past three days.

2. As Chairman of the Organizing Committee of the 8th APA, I once again would like to express my deep and heartfelt gratitude for the valuable achievements that the Plenary has achieved. These remarkable achievements stem from the great joint efforts with the deep responsibilities and commitment of all honorable delegates, under the wise leadership of Samdech Akka Moha Ponhea Chakrei HENG Samrin, President of APA.

**Sadmech, Honorable Delegates,**

**Excellencies, Ladies and gentlemen,**

3. The 8th APA that comes to an end in a few minutes was held in a delightful, and close solidarity and a cooperative manner among all distinguished participants, especially honorable heads, members of APA member parliaments, observer parliaments and partner organizations that have help accomplish remarkable success and fruitful results.

4. The general discussion of the plenary session on "Promoting Peace, Reconciliation and Dialogue in Asia" was conducted in an active atmosphere in which all heads of delegations of the APA members, observer parliaments and partner organizations had a chance to deliver statements, clearly emphasizing the importance and necessities of Peace which is a key factor and prerequisite for building and developing Asian nations by ensuring our beloved people live in peace, stability, prosperity and harmony. The statements stressed their concern and dissatisfaction over recent challenges and incidents in the region and in the world, especially ISIS, aggression and terrorism that have killed thousands of innocent people. Moreover, the statements demonstrated dissatisfactory, opposition and condemnation of the use of military forces to resolve the problems which causes more complicated troubles. Solving problems in peaceful ways, through bilateral or multilateral dialogues is an effective and sustainable choice.

5. The meetings of the Standing, Special and Ad-Hoc Committees also went smoothly with active discussions, exchanges of ideas and experiences, based on deep responsibility for the common issues affecting our region. These include eradication of extreme poverty, terrorism, extreme violence, human trafficking, drugs,

smuggling of cultural objects, gender, climate change, equity, tackling corruption and migration. Challenges, measures and solutions for those issues will be reported by Chairs of each Committee in a few minutes.

**Samdech, Honorable Delegates,**

**Excellencies, Ladies and Gentlemen,**

6. The Standing Committees have finally adopted 18 draft resolutions that are being submitted to the assembly for adoption. These important resolutions are the achievements that resulted from our utmost efforts with strong commitment and deep responsibility from all distinguished Members of Parliaments who are the representatives of Asian peoples to ensure peace, stability, prosperity for our peoples.

7. It is obvious that since the Asian Parliamentary Assembly was established, there have been a number of resolutions adopted whose implementation has not yet been fully enforced. These require us to further consolidate our efforts, especially at least to consider the possibility of including some elements in our national laws. At the same time, I appeal to all Honorable Delegates of APA member parliaments to encourage our respective governments to effectively implement all those resolutions.

**Samdech, Honorable Delegates,**

**Excellencies, Ladies and Gentlemen,**

8. Once again, as the Host and Chairman of the Organizing Committee of the 8th APA Plenary, I would like to express my profound gratitude and thanks to all Honorable Delegates, national and international guests for your valuable and tremendous contribution to the great success of this Plenary.

9. Finally, I would like to offer best wishes of good health and success to all delegations and a safe trip back home with good memories you have during you stay in our beautiful Land of Angkor, the Kingdom of Wonder, Cambodia

**Thank you for your attention**

**សន្ទរកថា**

**របស់ ឯកឧត្តមបណ្ឌិត ឈួន ញ៉ិលអនុប្រធានទី២ រដ្ឋសភា**

**នៃព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងក្នុងពិធីបិទមហាសន្និបាតលើកទី៨ របស់សភាតំបន់អាស៊ី**

**"ការជម្រុញសន្តិភាព ការផ្សះផ្សា និងកិច្ចសន្ទនាក្នុងតំបន់អាស៊ី"**

**ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៥**

---

*សូមគោរព:*

*- សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានសភាតំបន់អាស៊ី (អេភីអេ) និងជាប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា*

*-ឯកឧត្តម លោកជំទាវ ប្រធាននិងសមាជិកគណៈប្រតិភូសភាសមាជិកអេភីអេ*

*-ឯកឧត្តមបណ្ឌិតម៉ាស៊ូឌអ៊ីស្វាមីអគ្គលេខាធិការអេភីអេស្តីទី*

*-ឯកឧត្តម លោកជំទាវលោក លោកស្រីភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ ជាទីមេត្រី!*

*សាយ័ន្តសួស្តី!*

**១**-*ថ្ងៃនេះជាថ្ងៃចុងក្រោយនៃមហាសន្និបាតលើកទី ៨របស់អេភីអេហើយក៏ជាថ្ងៃដែលយើងទាំងអស់គ្នាមានអារម្មណ៍ធូរស្រាលនិងសប្បាយរីករាយបន្ទាប់ពីបានបំពេញការងារយ៉ាងសកម្មនិងយ៉ាងនឿយហត់ក្នុងកិច្ចប្រជុំអស់រយៈពេល៤ ថ្ងៃកន្លងមកនេះ។*

**២**- *ក្នុងន័យនេះ តាងនាមឲ្យគណៈកម្មាធិការរៀបចំមហាសន្និបាតលើកទី៨នៃសភាតំបន់អាស៊ី* (*អេ-ភី-អេ*) *និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណសារជាថ្មីនិងយ៉ាងជ្រាលជ្រៅបំផុតចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អ្នកទាំងអស់គ្នា និងសូម*

វាយតម្លៃខ្ពស់ចំពោះសមិទ្ធិផលដ៏មានតម្លៃដែលមហាសន្និបាតសម្រេចបាននាពេលនេះ។ សមិទ្ធិផលទាំងនេះ កើតចេញពីកិច្ចខិតខំប្រឹងប្រែងរួមរបស់យើងទាំងអស់គ្នា ប្រកបដោយស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់របស់ឯកឧត្តម លោកជំទាវ ប្រធាន និងសមាជិក សមាជិកា នៃសភាសមាជិកអេភីអេ និងអគ្គលេខាធិការសភាអេភីអេ និងជាពិសេសក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និង ឈ្វាសវៃរបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានអេភីអេ ។

៣- ជាការពិតណាស់ មហាសន្និបាតលើកទី៨ អេភីអេ ដែលនឹងត្រូវបញ្ចប់ក្នុងពេលបន្តិចទៀតនេះ បានប្រព្រឹត្តិទៅក្រោមបរិយាកាសដ៏រីករាយ ស្និទ្ធស្នាល សាមគ្គីភាពនិងសហប្រតិបត្តិការខ្ពស់ពីគ្រប់សំណាក់ភាគីពាក់ព័ន្ធ ជាពិសេសពីសំណាក់ឯកឧត្តមលោកជំទាវ ប្រធាន សមាជិកគណៈប្រតិភូសភាសមាជិក អេ ភីអេ ប្រទេសសង្កេតការណ៍ និងអង្គការដៃគូរបស់អេភីអេ ដែលបានញុំាងឲ្យសន្និបាតរបស់យើងទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ និងសម្រេចបាននូវលទ្ធផលគួរជាទីមោទនៈ។

៤-កិច្ចពិភាក្សាទូទៅ នៃកិច្ចប្រជុំពេញអង្គ ក្រោមមូលបទ "ការជម្រុញសន្តិភាព ការផ្សះផ្សានិងកិច្ចសន្ទនាក្នុងតំបន់អាស៊ី"បានប្រព្រឹត្តទៅយ៉ាងផុលផុសដោយប្រធានប្រតិភូនៃសភាសមាជិកអេភីអេ និងប្រទេសសង្កេតការណ៍បានធ្វើសេចក្តី ថ្លែងគ្រប់ៗគ្នាដោយបានបញ្ជាក់យ៉ាងច្បាស់ និងសង្កត់ធ្ងន់អំពី សារៈសំខាន់ និង ភាពចាំបាច់នៃសន្តិភាពដែលជាកត្តាគន្លឹះក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ ដោយធ្វើឲ្យប្រជាពលរដ្ឋបានរស់ក្នុងសុខសន្តិភាព ស្ថិរភាព វិបុលភាព និងសុខដុមរម្យនា។

ប្រតិភូទាំងអស់បានសម្តែងក្តីបារម្ភនិងមិនពេញចិត្តអំពីបញ្ហាប្រឈមថ្មីៗដែលកំពុងកើតមានឡើងនៅក្នុងតំបន់ ក៏ដូចជាសកលលោក ជាពិសេសអំពី ភេរវកម្មរបស់ក្រុម **ISIS**ដែលបានសម្លាប់ប្រជាពលរដ្ឋស្លូតត្រង់អស់រាប់ពាន់នាក់ៗទន្ទឹមនឹងនេះសេចក្តីថ្លែងការណ៍ក៏បានសម្តែងនូវការមិនពេញចិត្តនិងគាំទ្រចំពោះចំណាត់ការណាមួយដែលប្រើប្រាស់កម្លាំងយោធាដើម្បីដោះស្រាយបញ្ហាដែលនេះវាមិនត្រឹមតែមិនអាចដោះស្រាយបញ្ហាបាននោះទេផ្ទុយទៅវិញវាបង្កឲ្យមានបញ្ហាកាន់តែស្មុគស្មាញដែលរិតតែពិបាកដោះស្រាយថែមទៀតៗ ការដោះស្រាយបញ្ហា តាមរយៈកិច្ចសន្ទនាប្រកបដោយសន្តិវិធី ជាលក្ខណៈទ្វេភាគី ឬពហុភាគីជាជម្រើសមួយដ៏សមស្របមានប្រសិទ្ធិភាព និងមានភាពយូរអង្វែងៗ

**៥**-កិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍កិច្ចប្រជុំគណៈកម្មការពិសេសនិងកិច្ចប្រជុំគណៈកម្មាធិការចំពោះកិច្ចនានាក៏បានប្រព្រឹត្តទៅយ៉ាងរលូនដោយមានការពិភាក្សាផ្លាស់ប្តូរទស្សនៈ យោបល់គ្នា យ៉ា ងផុលផុសឈរលើស្មារតីទទួលខុសត្រូវខ្ពស់ សាមគ្គីភាព និងយោគយល់គ្នាទៅវិញទៅមក លើបញ្ហាសំខាន់រួមរបស់តំបន់អាស៊ីជាអាទិ៍ ការលុបបំបាត់ភាពក្រីក្រ អំពើ ភេរវកម្ម អំពើហឹង្សាជ្រុលនិយម ការជួញដូរមនុស្ស និងគ្រឿងញៀន បញ្ហាស្ត្រី និងសមភាពយេនឌ័រការប្រឆាំងអំពើពុករលួយ និងបញ្ហាទេសន្តប្រវេស្តជាដើមៗ បញ្ហាប្រឈម វិធានការនិងដំណោះស្រាយនឹងត្រូវរាយការណ៍ដោយប្រធានគណៈកម្មាធិការមួយៗក្នុងពេលបន្តិចទៀតនេះៗ

***សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!***

៦-ក្នុងរយៈពេល ៤ ថ្ងៃកន្លងមកនេះ គណៈកម្មការអចិន្ត្រៃយ៍ និង គណៈកម្មការ ចំពោះកិច្ចបានអនុម័ត សេចក្តីព្រាងសេចក្តីសម្រេចចំនួន ១ ៨ ដែលនឹងដាក់ជូន មហាសន្និបាតអនុម័តក្នុងពេលបន្តិចទៀតនេះ។ សេចក្តីព្រាងសំខាន់ៗ ទាំងអស់នេះ ជាសមិទ្ធិផលផ្លែផ្កាដែលកើតចេញពីកិច្ចខិតខំរួមពោរពេញដោយឆន្ទៈមោះមុត និង ស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាសភា សមាជិកអេភីអេដែលជាអ្នកតំណាងឲ្យប្រជាពលរដ្ឋអាស៊ីទាំងមូល ក្នុងការស្វែងរក និងជានាឲ្យបាននូវសុខសន្តិភាព ស្ថិរភាព វិបុលភាព និង សុខមាលភាពជូន ប្រជាពលរដ្ឋរបស់យើង។

៧-ជាការពិតណាស់ ចាប់តាំងពី អេភីអេចាប់បង្កើតឡើង យើងបានអនុម័ត និងដាក់ចេញនូវសេចក្តីសម្រេចជាច្រើន ក៏ប៉ុន្តែការអនុវត្តសេចក្តីសម្រេចទាំងអស់នោះនៅមិនទាន់មានភាពពេញលេញនៅ ឡើយដែលតម្រូវឲ្យយើងទាំងអស់គ្នាបន្តកិច្ចប្រឹងប្រែងថែមទៀត ជាពិសេសពិនិត្យ មើលពីលទ្ធភាពក្នុងការដាក់បញ្ចូលទៅក្នុងច្បាប់ជាតិរបស់ខ្លួន តាមតែអាចធ្វើទៅ បាន។ ទន្ទឹមនឹងការលើកទឹកចិត្ត និងជម្រុញដល់រដ្ឋាភិបាលរៀងៗខ្លួនក្នុងការ អនុវត្តនូវសេចក្តីសម្រេចទាំងនោះ។

**សម្តេច លោកជំទាវ ឯកឧត្តម លោក លោកស្រី ជាទីមេត្រី!**

៨- ជាថ្មីម្តងទៀតក្នុងនាមជាម្ចាស់ផ្ទះរៀបចំមហាសន្និបាត និងជាប្រធានគណៈ កម្មការធិការរៀបចំមហាសន្និបាតលើកទី៨អេភីអេ ខ្ញុំសូមថ្លែងអំណរគុណសារជាថ្មី ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំង

អស់ដែលបានរួមចំណែកយ៉ាងសំខាន់ធ្វើឲ្យមហាសន្និបាតនាពេលនេះបញ្ចប់ទៅ ទទួលបានជោគជ័យគួរជាទីមោទនៈ។

**៩**-ជាទីបញ្ចប់ខ្ញុំសូមគោរពជូនពរដល់ភ្ញៀវកិត្តិយសទាំងអស់សូម ទទួលបាននូវ សុខភាពល្អនិងជោគជ័យគ្រប់ភារៈកិច្ចនិងសូមឲ្យការធ្វើដំណើរ វិលត្រឡប់ទៅមាតុភូមិរបស់ខ្លួនប្រកបដោយសុវត្ថិភាព និងពាំនាំយកនូវអនុស្សាវរីយ៍ល្អៗពីមាតុភូមិអង្គរបវរនៃយើង ។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់**